ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងរដ្ឋប្បវេណីលេខៈ ១៥៦
ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០
សាលក្រមលេខៈ ១៤ (ថ)
ចុះថ្ងៃទី២០/០៤/២០២០

## តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០

**សមាសភាពជំនុំជម្រះ**

- លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល
- លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

- ដើមចោទឈ្មោះ [redacted] ស៊ីនួន ភេទស្រី កើតឆ្នាំ១៩៧៨ សញ្ជាតិខ្មែរ មានអាសយដ្ឋាន [redacted]

មានអ្នកតំណាងដោយអាណត្តិ មេធាវី [redacted] និងមេធាវី [redacted]

- ចុងចម្លើយឈ្មោះ [redacted] សុខុន ភេទប្រុស កើតឆ្នាំ១៩៧៥ មានអាសយដ្ឋាន [redacted]

## អង្គហេតុ និង ចំណុចវិវាទ

១. សាលក្រមដែលទាមទារដោយដើមចោទ

ប្តឹងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

១.១.សុំលែងលះជាមួយឈ្មោះ [redacted] សុខុន ភេទប្រុស ថ្ងៃខែឆ្នាំកំណើត១០-០៥-១៩៧៥ មានអាសយដ្ឋាន [redacted]។

១.២.សុំសិទ្ធិគ្រប់គ្រងអំណាចមេបាលើកូនទាំង ២នាក់ ដូចខាងក្រោម៖

-ឈ្មោះ [redacted] វាសនា ភេទស្រី ថ្ងៃខែឆ្នាំកំណើត១៧-០៥-២០០១ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋាន [redacted] មានសំបុត្របញ្ជាក់កំណើតលេខ ១៤៨៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំព្រែកតាទែន និងមានសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ៣៣៨/១៧ ស.ព.ឮ របស់អភិបាលស្រុកពញាឮ ខេត្តកណ្តាល។

-ឈ្មោះ [redacted] មួយលី ភេទស្រី កើតថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ មានសំបុត្រកំណើតលេខ ៨២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១ មានសំបុត្របញ្ជាក់កំណើតលេខ ៨២ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១១ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំព្រែកតាទែន។

១.៣.សុំបែងចែកទ្រព្យសម្បត្តិរួមលើដី-ផ្ទះទំហំ ទទឹង ៦ម៉ែត្រ បណ្តោយ ៩ម៉ែត្រ ដែលមានទីតាំងស្ថិតក្នុង ភូមិស្លែងដីដុះ ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល។

២. ការពន្យល់គ្រួសៗអំពីរឿងក្តី

រឿងក្តីនេះ ជារឿងក្តីដែលដើមចោទប្តឹងសុំលែងលះពីចុងចម្លើយ សុំសិទ្ធិគ្រប់គ្រងកូន និងសុំចែកទ្រព្យសម្បត្តិរួម ដោយសារ កាលពីអំឡុងឆ្នាំ២០០០ ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ បន្ទាប់ពីរៀបការ បានរួមរស់ជាមួយគ្នា ដើមចោទ និងចុងចម្លើយ បានបង្កើតកូនពីរនាក់ ដែលមានឈ្មោះ [redacted] វាសនា ភេទស្រី កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០១ មានសំបុត្រកំណើតលេខ ១៤៨៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងឈ្មោះ [redacted] មួយលី ភេទស្រី កើតថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ មានសំបុត្រកំណើតលេខ ៨២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១។ ក្នុងការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយក៏មានទ្រព្យសម្បត្តិរួម ដី-ផ្ទះទំហំ ទទឹង ៦ម៉ែត្រ បណ្តោយ ៩ម៉ែត្រ ដែលមានទីតាំងស្ថិតក្នុងភូមិស្លែងដីដុះ ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល ផងដែរ។ ហើយក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើមចោទ និងចុងចម្លើយ មានភាពរកាំរកូសឈ្លោះប្រកែកគ្នាជាញឹកញាប់ ដោយសារតែចុងចម្លើយឈ្មោះ [redacted] សុខុន ជា

Scanned with CamScanner

មនុស្សញៀនស្រា និងតែងតែប្រើហិង្សាវាយធ្វើបាបលើដើមចោទឈ្មោះ [redacted] ស៊ីនួន ព្រមទាំងស្រែកជេរប្រមាថ មកលើដើមចោទជាញឹកញាប់ផងដែរ។ ទង្វើរបស់ចុងចម្លើយដែលធ្វើទៅលើដើមចោទនេះ ធ្វើឱ្យដើមចោទមានការឈឺចាប់ក្នុងចិត្ត អស់អាឡោះអាល័យ និងអស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្តីប្រពន្ធជាមួយគ្នាតទៅទៀតឡើយ។

៣. ចំណុចវិវាទ និងចំណុចគ្មានវិវាទ

៣.១. ចំណុចវិវាទ: គ្មាន

៣.២ .ចំណុចគ្មានវិវាទ:

១.យល់ព្រមលែងលះគ្នា

២.សិទ្ធិគ្រប់គ្រងកូន ទុកសិទ្ធឱ្យកូនទាំងពីរនាក់ជាអ្នកសម្រេចចិត្ត

៣.ការបែងចែកទ្រព្យសម្បត្តិ លក់ចែកគ្នាជាពីរចំណែកស្មើគ្នាតាមតម្លៃជាក់ស្តែង

៤. ការអះអាងរបស់គូភាគី

៤.១. ការអះអាងរបស់ដើមចោទ និងចុងចម្លើយ

- ដើមចោទ និងចុងចម្លើយបានអះអាងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដូចគ្នាថា ខ្លួនព្រមព្រៀងសះជានឹងគ្នាដូចខាងក្រោម៖

១.ដើមចោទ និងចុងចម្លើយ ពួកព្រមព្រៀងលែងលះគ្នា ចាប់ពីថ្ងៃនេះតទៅ

២.ចំពោះទ្រព្យសម្បត្តិមានផ្ទះមួយខ្នង ពួកខ្លួនសុខចិត្តលក់ចែកគ្នាជាពីរចំណែកស្មើរគ្នាទៅតាមតម្លៃជាក់ស្តែង។

៣.ចំណែកកូនចំនួន ២ នាក់ មានឈ្មោះ [redacted] វាសនា ភេទស្រី កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០១ មានសំបុត្រកំណើតលេខ ១៤៨៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងឈ្មោះ [redacted] មួយលី ភេទស្រី កើតថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ មានសំបុត្រកំណើតលេខ ៨២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១ ពួកខ្លួនទុកសិទ្ធិឱ្យកូនជាអ្នកសម្រេចចិត្តថា រស់នៅជាមួយឪពុក ឬរស់នៅជាមួយម្តាយ ។

៤.២. ការអះអាងរបស់កូនស្រីទាំងពីររបស់គូភាគី

-ឈ្មោះ [redacted] វាសនា បានឆ្លើយថា ខ្លួនជាសិស្សរៀនថ្នាក់ទី១២។ ពេលឪពុកម្តាយលែងលះគ្នា ខ្លួនសុខចិត្តទៅរស់នៅជាមួយម្តាយឈ្មោះ [redacted] ស៊ីនួន ព្រោះនៅជាមួយម្តាយស្រួលជាង បើនៅជាមួយឪពុកពេលគាត់ផឹកស៊ីស្រវឹងមករករឿងខ្លួនរហូត។

-ឈ្មោះ [redacted] មួយលី បានឆ្លើយថា ខ្លួនជាសិស្សរៀនថ្នាក់ទី៩។ ពេលឪពុកម្តាយលែងលះគ្នា ខ្លួនសុខចិត្តទៅរស់នៅជាមួយម្តាយឈ្មោះ [redacted] ស៊ីនួន ព្រោះនៅជាមួយម្តាយស្រួលជាង បើនៅជាមួយឪពុកពេលគាត់តែងតែជេរបញ្ចោរ និងដេញខ្លួនចេញពីផ្ទះជាញឹកញ៉ាប់។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យឥស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖

១-ដើមចោទ និងចុងចម្លើយអះអាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដូចគ្នាថា ខ្លួននៅតែរក្សាការព្រមព្រៀងគ្នាដូចក្នុងកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០ ដដែលដោយបានព្រមព្រៀងគ្នាដូចតទៅ៖

-ដើមចោទ និងចុងចម្លើយ ព្រមព្រៀងលែងលះគ្នា ចាប់ពីថ្ងៃនេះតទៅ

-ចំពោះទ្រព្យសម្បត្តិរួមមានដី និងផ្ទះមួយខ្នងទំហំ ទទឹង ៦ម៉ែត្រ បណ្តោយ ៩ម៉ែត្រ ដែលមានទីតាំងស្ថិតក្នុងភូមិស្លែងជីដុះ ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល ពួកខ្លួនសុខចិត្តលក់ចែកគ្នាជាពីរចំណែកស្មើរគ្នាទៅតាមតម្លៃជាក់ស្តែង។

-ចំណែកកូនចំនួន ២ នាក់ មានឈ្មោះ [redacted] វាសនា ភេទស្រី កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០១ មានសំបុត្រកំណើតលេខ ១៤៨៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងឈ្មោះ [redacted] មួយលី ភេទស្រី កើតថ្ងៃទី០១

Scanned with CamScanner

ខែមករា ឆ្នាំ២០០៥ មានសំបុត្រកំណើតលេខ ៨២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១ ពួកខ្លួនទុកសិទ្ធិឱ្យកូនជាអ្នកសម្រេចចិត្តថា រស់នៅជាមួយឪពុក ឬរស់នៅជាមួយម្តាយ។

គប្បីតុលាការសម្រេចតាមការព្រមព្រៀងគ្នានេះ លើកលែងតែចំណុចប្តឹងសុំលែងលះ តុលាការមិនលើកយកពិចារណាទេ។

២-យោងសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ៣៣៨/១៧ ស.ព.ព្ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ដែលចេញដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រុកពញាឮ ខេត្តកណ្តាល និងសំបុត្របញ្ជាក់កំណើតលេខ ៨២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១ ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំព្រែកតាទែន អាចបញ្ជាក់បានថា ឈ្មោះ [redacted] ស៊ីនួន និងឈ្មោះ [redacted] សុខុន ពិតជាមានកូនស្រីពីរនាក់ ដែលមានឈ្មោះ [redacted] វាសនា ភេទស្រី កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០១ និងឈ្មោះ [redacted] មួយលី ភេទស្រី កើតថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ប្រាកដមែន។

៣-តាមការអះអាងរបស់កូនទាំងពីរនាក់របស់គូភាគី

៣.១.ឈ្មោះ [redacted] វាសនា បានឆ្លើយថា ខ្លួនជាសិស្សរៀនថ្នាក់ទី១២។ ពេលឪពុកម្តាយលែងលះគ្នា ខ្លួនសុខចិត្តទៅរស់នៅជាមួយម្តាយឈ្មោះ [redacted] ស៊ីនួន ព្រោះនៅជាមួយម្តាយស្រួលជាង បើនៅជាមួយឪពុកពេលគាត់ផឹកស៊ីស្រវឹងមករករឿងខ្លួនរហូត។

៣.២.ឈ្មោះ [redacted] មួយលី បានឆ្លើយថា ខ្លួនជាសិស្សរៀនថ្នាក់ទី៩។ ពេលឪពុកម្តាយលែងលះគ្នា ខ្លួនសុខចិត្តទៅរស់នៅជាមួយម្តាយឈ្មោះ [redacted] ស៊ីនួន ព្រោះនៅជាមួយម្តាយស្រួលជាង បើនៅជាមួយឪពុកពេលគាត់តែងតែជេរបញ្ចោរ និងដេញខ្លួនចេញពីផ្ទះជាញឹកញាប់។

៤-ចំពោះការប្តឹងសុំលែងលះពីចុងចម្លើយ និងការបែងចែកទ្រព្យសម្បត្តិរួមរបស់ដើមចោទ តុលាការយល់ឃើញដូចក្នុងចំណុចទី១ នៃសំអាងហេតុនៃសាលក្រមនេះ។ ឯចំពោះសិទ្ធិគ្រប់គ្រងកូន តុលាការយល់ឃើញដូចក្នុងចំណុចទី១ ចំណុចទី២ និងទី៣ នៃសំអាងហេតុនៃសាលក្រមនេះ។

៥-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១.ប្រគល់សិទ្ធិគ្រប់គ្រងលើកូនស្រីពីរនាក់ ដែលមានឈ្មោះ [redacted] វាសនា ភេទស្រី កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០១ និងឈ្មោះ [redacted] មួយលី ភេទស្រី កើតថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ទៅឱ្យដើមចោទជាម្តាយឈ្មោះ [redacted] ស៊ីនួន តែត្រូវទុកសិទ្ធិឱ្យចុងចម្លើយឈ្មោះ [redacted] សុខុន ជាឪពុកអាចទៅសួរសុខទុក្ខកូនតាមច្បាប់បាន។

២.ទ្រព្យសម្បត្តិរួមមានដី និងផ្ទះទំហំ ទទឹង ៦ម៉ែត្រ បណ្តោយ ៩ម៉ែត្រ ដែលមានទីតាំងស្ថិតក្នុងភូមិស្លែងដីដុះ ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល លក់ចែកគ្នាជាពីរចំណែកស្មើគ្នាតាមតម្លៃជាក់ស្តែង។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ.................ខែ.............ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កណ្តាល ថ្ងៃទី..............ខែ.......... ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]